# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## កំណត់ហេតុ

## ស្តីពី

## កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ សិក្ខាសាលាខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី

ឆ្នាំពីរពាន់ប្រាំពីរ ខែមិថុនា ថ្ងៃទី ម្ភៃប្រាំបី វេលាម៉ោងប្រាំបី នៅខេត្តស្ទឹងត្រែងមានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **សំ សុខផល** ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងពិភាក្សាលើការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដោយមានការចូលរួមពីសំណាក់ ឯកឧត្តម **ឡូយ សូផាត** អភិបាលខេត្ត ស្ទឹងត្រែង និងឯកឧត្តម **ថង សាវុន** អភិបាលរងខេត្តរតនៈគិរី។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ឡូយ សូផាត** អភិបាលរងខេត្តស្ទឹងត្រែង បានធ្វើការស្វាគមន៍ចំពោះគណៈអធិបតី និងថ្លែងអំណរគុណ ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីការកែទម្រង់ច្បាប់ និងតុលាការនេះ ដើម្បីផ្តល់ជាព័ត៌មាន និងបទពិសោធន៍ផ្សេងៗដល់មន្ត្រីរបស់ស្ថាប័នជំនាញផ្សេងៗ នៅតាមបណ្តាខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត។ ឯកឧត្តមមានការចាប់អារម្មណ៍ផងដែរថា វិស័យកំណែទម្រង់ច្បាប់ និងតុលាការនេះជាអាទិភាពមួយដ៏ចាំបាច់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជាយើងដែលត្រូវតែធ្វើជាបន្ទាន់ ហើយឯកឧត្តមសង្ឃឹមថា សហការីមកពីមន្ទីរស្ថាប័នជំនាញផ្សេងៗជុំវិញខេត្តស្ទឹងត្រែង និងខេត្តរតនគិរី នឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាក្នុងអង្គសិក្ខាសាលានេះ។ ជាមួយគ្នានោះផងដែរ ឯកឧត្តមបានបង្ហាញនូវការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការអនុវត្តការងារនេះរបស់ខេត្តស្ទឹងត្រែង ហើយឯកឧត្តមសង្ឃឹមថា សកម្មភាពកំណែទម្រង់របស់ខេត្តស្ទឹងត្រែងនេះនឹងអាចដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាលទាំងស្រុង ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនេះ។

បន្ទាប់ពីសន្ទរកថា របស់ឯកឧត្តមអភិបាលខេត្តស្ទឹងត្រែង ឯកឧត្តម **សំ សុខផល** បានធ្វើបទអន្តរាគមន៍ជម្រាបជូនអង្គសិក្ខាសាលាអំពីដំណើរការរីកចំរើនរបស់កំណែទម្រង់ច្បាប់ និងតុលាការនេះ បន្ទាប់ពីមានដំណើរការអស់រយៈពេលបីឆ្នាំមកហើយ។ កំណែទម្រង់៤ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទីបីនៃរដ្ឋសភា គឺមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងទ័ព កំណែទម្រង់ច្បាប់ និងតុលាការ និងការប្រឆាំងអំពើពុករលួយ។ ជាមួយគ្នានោះឯកឧត្តមបានជម្រាបជូនថា យើងធ្វើកំណែទម្រង់សព្វបែបយ៉ាងក្នុងគោលដៅរួមមួយគឺអភិបាលកិច្ចល្អ ហើយឯកឧត្តមបានបញ្ជាក់ទៀតថា បើរាជរដ្ឋាភិបាលមានគោលនយោបាយជាតិប្រកបដោយអភិបាលកិច្ចល្អ ប្រទេសជាតិយើងនឹងមានការអភិវឌ្ឍន៍រីកចំរើនទៅមុខយ៉ាងប្រាកដ។

ឯកឧត្តមប្រធានបានជម្រាបជូនអង្គសិក្ខាសាលាទាំងមូល អំពីដំណើរការនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ២០០០ មក។ ចាប់ពីពេលនោះមកក្រុមការងារមួយត្រូវបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ ហើយនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ យុទ្ធសាស្ត្រនៃកំណែទម្រង់ច្បាប់ និងតុលាការនេះ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសកម្មភាពសម្រាប់អនុវត្តជាយុទ្ធសាស្ត្រ។

កម្មវិធីសកម្មភាពនេះចែកចេញជាបីដំណាក់កាល ៖

- ផែនការសកម្មភាពរយៈពេលខ្លី
- ផែនការសកម្មភាពរយៈពេលមធ្យម និង
- ផែនការសកម្មភាពរយៈពេលវែង។

បន្ទាប់ពីបទអន្តរាគមន៍របស់ឯកឧត្តមប្រធាន លោក **សោ សាធុន** ប្រធានតុលាការខេត្តស្ទឹងត្រែង បានមានប្រសាសន៍ថា ដើម្បីប្រែក្លាយប្រទេសជាតិរបស់យើងឱ្យទៅជានីតិរដ្ឋបាន លុះត្រាណាតែគោរពប្រតិបត្តិឱ្យបានត្រឹមត្រូវទៅតាមច្បាប់ដែលមាន។ លោកមានប្រសាសន៍បន្ថែមទៀតថា ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលស្របនឹងទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលអាណត្តិទី៣នៃរដ្ឋសភានេះ នឹងអាចធ្វើឱ្យសង្គមមានភាពល្អប្រសើរឡើង។ ម្យ៉ាងទៀតអាចជាគន្លឹះទាក់ទាញអ្នកវិនិយោគទុនឱ្យគេមកបណ្តាក់ទុនរកស៊ីនៅកម្ពុជាផងដែរ។

- លោកបានលើកឡើងពីភាពឯករាជ្យរបស់តុលាការថា មិនមែនតុលាការខ្លួនឯងចង់ធ្វើអ្វីក៏បាននោះទេ គឺឯករាជ្យ-ភាពនៅត្រង់ថា ចៅក្រមធ្វើការកាត់ក្តីពុំមានការបង្ខំ ឬគាបសង្កត់ពីអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញាតិ ឬជនណាម្នាក់ឡើយ។ មិនតែប៉ុណ្ណោះតុលាការត្រូវគោរពក្រមសីលធម៌សម្រាប់វិជ្ជាជីវៈរបស់ខ្លួន។
- បញ្ហាកកស្ទះសំណុំរឿងអាចដោះស្រាយបាន អាស្រ័យទៅលើការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់ទាំងផ្នែកកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ទាំងផ្នែកមន្ទីរជំនាញពាក់ព័ន្ធគ្រប់ប្រភេទ រហូតដល់មូលដ្ឋាន ភូមិ ឃុំផងដែរ។
- ដើម្បីឱ្យតុលាការដំណើរការល្អ ត្រូវឈរលើមូលដ្ឋានក្រមសីលធម៌ត្រឹមត្រូវ។ សាលក្រម សាលដីកាមានគតិបណ្ឌិត។ ត្រូវមានការទទួលខុសត្រូវនៅចំពោះមុខច្បាប់ និងការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទាំងអស់។

- ចំណុចខ្វះខាតមួយចំនួន ដែលទាក់ទិនទៅនឹងការអនុវត្តច្បាប់របស់តុលាការខេត្តកន្លងមក គឺការមិនបានចូលរួមប្រគល់ដីកាកោះ សាលក្រម សាលដីកា ឬដំណាក់ការផ្សេងៗអំពីតុលាការ ជូនកាលដោយការមិនបានចាប់អារម្មណ៍ទៅលើបញ្ហាដីកាកោះ ឬជួនកាលដីកានោះត្រូវបានគេទុកចោល។

លោក **យ៉ា ឈារិន** ប្រធានតុលាការខេត្តរតនគីរី បានចាប់អារម្មណ៍ទៅលើការកែទម្រង់ច្បាប់ និងតុលាការ ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាយុត្តិសាស្ត្រដ៏សំខាន់មួយ ក្នុងចំណោមយុត្តិសាស្ត្រជាអាទិភាពផ្សេងៗទៀត។ ជាមួយគ្នានោះ លោកបានរំលឹកឡើងវិញ និងប្រៀបធៀបច្បាប់ប្រទេសកម្ពុជាយើង កាលពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យឥឡូវនេះថា វាមានភាពខុសគ្នាដោយច្បាប់កាលពីសម័យមុនមិនទាន់មានភាពទូលំទូលាយ ហើយច្បាប់បច្ចុប្បន្នមានលក្ខណៈប្រសើរជាងមុន ប៉ុន្តែក៏មិនទាន់ជាមានលក្ខណៈស៊ីជម្រៅ និងសមស្របតាមស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះដែរ ដូច្នេះហើយបានជាយើងត្រូវតែកែទម្រង់ច្បាប់ និងតុលាការ ដើម្បីឱ្យច្បាប់របស់យើងមានប្រសិទ្ធិភាពក្នុងការ ការពារសិទ្ធិសេរីភាព ផលប្រយោជន៍របស់ប្រជាពលរដ្ឋបានពេញលេញ ឱ្យស្របទៅតាមចរន្តសេដ្ឋកិច្ច និងនយោបាយនៅលើពិភពលោក។ លោកបានមានប្រសាសន៍បន្ថែមទៀតថា ប្រទេសយើងមានការអនុម័តច្បាប់ជាច្រើន ដូច្នេះយើងត្រូវតែអនុវត្តអោយបានត្រឹមត្រូវទៅតាមច្បាប់ដែលមាន។ លោកបានជម្រាបផងដែរថា ក្រមនីតិវិធីរដ្ឋប្បវេណី យើងបានអនុម័តតាមជប៉ុន ដោយយកមូលដ្ឋានពីប្រទេសជប៉ុន ដែលជាប្រទេសមានសក្តានុពលផ្នែក សេដ្ឋកិច្ចដ៏ខ្លាំងក្លា ចំណែកក្រមនីតិវិធីព្រហ្មទណ្ឌ គឺយើងអនុម័តតាមបារាំង។ ក្នុងវិស័យកែទម្រង់នេះ រាជរដ្ឋាភិបាលបានប្រឹងប្រែងបង្កើនសមត្ថភាពចៅក្រមជាច្រើន ដោយកន្លងមកយើងពុំទាន់មានសាលាចៅក្រមនៅឡើយទេ។ កាលពីសម័យអតីតរដ្ឋកម្ពុជា យើងបានជ្រើសរើសចៅក្រមនៅតាមក្រសួងមន្ទីរផ្សេងៗ ដែលពុំមានជំនាញវិជ្ជាជីវៈជាអ្នកច្បាប់ និងពុំធ្លាប់ឆ្លងកាត់សាលាចៅក្រមនោះដែរ។ ដូច្នេះបញ្ហាកែទម្រង់ច្បាប់ និងតុលាការនេះវាជារឿងសំខាន់ណាស់ ហើយពេលថ្មីៗកន្លងទៅនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានខិតខំពង្រាងបង្កើតក្រមសីលធម៌អង្គចៅក្រម ដើម្បីឱ្យចៅក្រមគោរពទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ លោកបានមានមតិផងដែរថា ការកែទម្រង់ច្បាប់ និងតុលាការនេះមានការរីកចំរើន និងមានការប្រែប្រួលយ៉ាងខ្លាំង តាំងពីនីតិវិធីនៃការអនុវត្តន៍ច្បាប់ និងនីតិវិធីនៃដំណើរការកាត់ក្តីជាដើម។ ការកែទម្រង់នេះបានខិតខំធ្វើយ៉ាងណាឱ្យមានទំនុកចិត្តពីមជ្ឈដ្ឋានខាងក្រៅ និងមជ្ឈដ្ឋានអន្តរជាតិ ដើម្បីឱ្យគេទទួលស្គាល់ថា ប្រទេសយើងមានការប្រែប្រួលទៅតាមលក្ខណៈអន្តរជាតិហើយ។ លោកប្រធានតុលាការខេត្តរតនគីរីក៏បានលើកអំពីបញ្ហាលំបាកក្នុងនីតិវិធីនៃការអនុវត្តច្បាប់ និងនីតិវិធីនៃដំណើរការកាត់ក្តីដែរបញ្ហាទាំងនោះមាន ៖

- បញ្ហាចៅក្រម នៅខេត្តរតនគីរី ចៅក្រមមាន២នាក់ ព្រះរាជអាជ្ញា ០១នាក់ និងក្រឡាបញ្ជី ០៧នាក់
- សម្រាប់ក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីធំៗ ដែលមានទឹកប្រាក់លើសពី៥លានឡើងទៅ លុះត្រាតែមានចៅក្រមបីរូបទើបធ្វើការជំរះក្តីបាន ។
- បញ្ហាមួយទៀតពាក់ព័ន្ធទៅនឹងមន្ត្រីនគរបាលយុត្តិធម៌ ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីបានបង្ខំឱ្យមន្ត្រីនគរបាលយកចិត្តទុកដាក់ជាប្រចាំ ហើយធ្វើការឱ្យបានលឿនទាន់សភាពការនៃដំណើរការកាត់ក្តី បើធ្វើមិនទាន់ទេ អាចធ្វើឱ្យមានការលំបាក។

- បញ្ហាមិនបញ្ជូនដីកាកោះ ឬបញ្ជូនព័ត៌មានផ្សេងៗជូនដល់ដៃ និងការយឺតយ៉ាវមិនបានបញ្ជូនដីកាកោះដល់ដៃ។ លោកបានបញ្ជាក់ថា បញ្ហានេះមិនមែនមានតែខេត្តរតនៈគីរីនោះទេ ខេត្តស្ទឹងត្រែងក៏មានបញ្ហានេះដែរ។

ឯកឧត្តម **ស៊ុយ ម៉ុខលាច** បានធ្វើបទអន្តរាគមន៍ និងធ្វើការបង្ហាញពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានលើកឡើងពីរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម **ឌិត មុន្ទី** ប្រធានតុលាការកំពូល សហប្រធានក.ក.ច.ន.យ។ បន្ទាប់មកឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីអង្គភាពនៅក្រោមឱវាទរបស់ក្រុមប្រឹក្សា ៖

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍(PCB) ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌។
- អង្គភាពគ្រប់គ្រងគម្រោង(PMU) ដែលបានបង្កើតឡើងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ។

ជាបន្ទាប់ឯកឧត្តមនាយកអង្គភាពគ្រប់គ្រងគម្រោង បានធ្វើការបង្ហាញអំពីកម្មវិធីសកម្មភាព ដែលមានក្នុងឯកសារសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលមានចែកជូនជាឯកសារស្រាប់ដល់អង្គសិក្ខាសាលានាពេលនោះ ព្រមទាំងធ្វើការពន្យល់ផែនការសកម្មភាពនីមួយៗ។ ឯកឧត្តមបានដកស្រង់យកចំណុចសំខាន់ៗខ្លះនៃឯកសារមកធ្វើអត្ថាធិប្បាយជូនអង្គសិក្ខាសាលាដូចជា បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់មានចែងក្នុងកម្មវិធីសកម្មភាពនេះ ៖

- បញ្ហាទប់ស្កាត់អំពើពុករលួយក្នុងតុលាការ
- បញ្ហាកកស្ទះសំណុំរឿងក្នុងតុលាការ។

ទន្ទឹមនឹងនោះឯកឧត្តមក៏បានជម្រាបជូនអំពីលទ្ធផល នៃការដោះស្រាយនូវបញ្ហាប្រឈមមុខមួយចំនួន ដែលតុលាការក្រុងភ្នំពេញបានដោះស្រាយរួចជាស្ថាពរនោះមាន ៖

- បញ្ហាខ្វះបន្ទប់សវនាការ
- បញ្ហាខ្វះមេធាវី
- បញ្ហាដឹកជញ្ជូនជនជាប់ចោទពីពន្ធនាគារចូលសវនាការ
- ការបង្វិលដីកាកោះ ជាដើម។ល។

ចំណែកបញ្ហាផ្សេងៗទៀតដូចជា ៖

១-បញ្ហាចៅក្រម គឺលោកប្រធានតុលាការក្រុងភ្នំពេញ ស្នើឱ្យមានការជ្រើសរើសឱ្យបានច្រើនរហូតដល់ទៅ ១០០នាក់ ក្នុងមួយឆ្នាំ ចំណែកឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានសម្រេចឱ្យជ្រើសរើស ចៅក្រម ៧០ នាក់ក្នុងមួយឆ្នាំ

២-បញ្ហាសាលក្រម ក្រុមប្រឹក្សាបានសម្រេចឱ្យមានការជ្រើសរើសសិស្សអាជ្ញាសាលា

៣-ការបោះពុម្ពសាលដីកា សាលក្រមរបស់តុលាការ

៤-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន

៥-ទាក់ទងជាមួយ E.C.C.C ដើម្បីរកថវិកាមករៀបចំគម្រោងពង្រីកបន្ថែមតុលាការគំរូ ដែលមាននៅខេត្ត កណ្តាល ក្រុងភ្នំពេញ ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ។

៦-អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង ខិតខំផ្សព្វផ្សាយបន្ថែមនូវការងាររបស់ខ្លួន និងរកជំនួយបន្ថែមសម្រាប់ជ្រើសរើសសេចក្តីសម្រេចរបស់តុលាការដាក់ឱ្យទៅជាយុទ្ធសាស្ត្រ ។

៧-ការរៀបចំតាក់តែងច្បាប់ បង្កើតតុលាការពាណិជ្ជកម្ម។

អង្គប្រជុំពិភាក្សានេះ បានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ដោយគ្មានសំណួរអ្វីពីអង្គសិក្ខាសាលាឡើយ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

នាយកអង្គភាពគ្រប់គ្រងគម្រោង

អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង

សេង វ៉ាន់ដា

ស៊ុន សិរីវុធ